# របាយការណ៍នៃវេទិការៀនសូត្រផ្នែកទំនាក់ទំនងព័ត៌មាន និងបច្ចេកវិទ្យា លើកទី៣១ ក្រោមប្រធានបទ

## “ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងសិទ្ធិឌីជីថល”

ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣

**ភោជនីយដ្ឋានទន្លេបាសាក់២។**





www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## 1. សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេមួយនៅក្នុងប្រទេសកម្ពុជា។ រហូតមកដល់ខែមិថុនា ឆ្នាំ២០២៣ អង្គការ គ.ស.ក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួន ១៨៦។ បច្ចុប្បន្ននេះ អង្គការ គ.ស.ក បានកំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៤ ពីឆ្នាំ២០២១ ដល់ ២០២៣។ កម្មវិធីនេះ មានគោលបំណងសំខាន់ចំនួនពីរ៖ ទី១ គឺធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និងទី២ មជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាព សម្រាប់អង្គការសង្គមស៊ីវិលទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។ ប្រព័ន្ធបច្ចេកវិទ្យាមានការរីកចម្រើនគួរអោយកត់សំគាល់នាទស្សវត្សចុងក្រោយនេះ។ ក្នុងពេលជាមួយគ្នានេះដែរ ប្រជាជនកម្ពុជាមានការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងបច្ចេកវិទ្យាកាន់តែទូលំទូលាយក្នុងវិស័យការងារនិងការរស់នៅប្រចាំថ្ងៃ។ សម្រាប់ប្រជាជនដែលរស់នៅទីជនបទក៏ពួកគាត់អាចប្រើប្រាស់អ៊ីនធឺណែតដើម្បីប្រើប្រាស់ facebook, telegram, Instagram, Tektok, ផងដែរ។ ដើម្បីធានាការប្រើប្រាស់ផ្នែកបច្ចេកវិទ្យានេះអោយកាន់តែមានសុវត្ថិភាព និងប្រសិទ្ធភាព ស្របតាមច្បាប់ និងក្របខ័ណ្ឌបទប្បញ្ញត្តិនានា រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រិត្យមួយចំនួនដូចជា៖ អនុក្រិត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណែតជាតិដែលបានបង្កើតឡើងនៅឆ្នាំ២០២១ និង អនុក្រិត្យស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីធឺណែត ជាដើម។ ចំពោះអង្គការសង្គមស៊ីវិលវិញ ការយល់ដឹងលើក្របខ័ណ្ឌបទប្បញ្ញត្តិទាំងនេះនៅមានកម្រិតនៅឡើយ ដូច្នេះអង្គការគសក នឹងធ្វើការរៀបចំវេទិការៀនសូត្រស្តីពីប្រព័ន្ធទំនាក់ទំនងបច្ចេកវិទ្យា ដោយផ្តោតសំខាន់លើប្រធានបទ **“ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងសិទ្ធិឌីជីថល”** នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ នៅភោជនីយដ្ឋានទន្លេបាសាក់២។

### គោលបំណងនៃវេទិកា

១) ដើម្បីទទួលបានការយល់ដឹងបន្ថែមអំពីក្របខ័ណ្ឌបទប្បញ្ញត្តិទាក់ទងនឹងបច្ចេកវិទ្យា និងសិទ្ធិឌីជីថល
២) ដើម្បីបង្កើតបណ្តាញ និងទំនាក់ទំនងកាន់តែច្រើនក្នុងចំណោមអ្នកអនុវត្ត និងអ្នកជំនាញផ្នែកទំនាក់ទំនងព័ត៌មាននិងបច្ចេកវិទ្យា សម្រាប់ការសិក្សាបន្តលើទំនាក់ទំនងព័ត៌មាននិងបច្ចេកវិទ្យា និងបញ្ហាពាក់ព័ន្ធផ្សេងៗ

## 2. ដំណើរការ

នៅក្នុងវេទិកានេះ មានអ្នកចូលរួមសរុប**៧១នាក់ (ស្ត្រី២១នាក់)** ដែលជាសមាជិកនៃអង្គការគសក។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

### 3.1. កិច្ចស្វាគមន៍

**លោកច័ន្ទ ភក្តី** ប្រធានកម្មវិធីផ្នែកសមាជិក និងការកៀរគរធនធាននៃអង្គការគសក មានចំណាប់អារម្មណ៍ដូចតទៅ៖

តាងនាមអោយអង្គការគណៈកម្មាធិការសហប្រតិបត្តិការនៅកម្ពុជា ខ្ញុំបាទសូមសំដែងការកោតសរសើរចំពោះថ្នាក់គ្រប់គ្រងគ្រប់ជាន់ថ្នាក់នៃអង្គការសមាជិកទាំងអស់ដែលតែងតែផ្តល់ឱកាសអោយសមាជិកក្រុមការងាររបស់ខ្លួនបានចូលរួមយ៉ាងសកម្មនៅគ្រប់វេទិការៀនសូត្រដែលរៀបចំដោយអង្គការគសក។

តាមរយៈការចូលរួមយ៉ាងសកម្មរបស់ក្រុមការងារទំនាក់ទំនងពត៌មាន និងបច្ចេកវិទ្យា អង្គការគសក បានរៀបចំវេទិការៀនសូត្រស្តីពី ទំនាក់ទំនងពត៌មាន និងបច្ចេកវិទ្យា ជាច្រើន។ វេទិកានេះ បានលើកយកនូវប្រធានបទសំខាន់ៗ មានប្រយោជន៍យ៉ាងច្រើន ដូចជា សុវត្ថិភាពអ៊ីនធឺណេត ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសង្គម(ហ្វេបុក តេឡេក្រាម) ប្រកបដោយសុវត្ថិភាព ឧបករណ៏ទំនាក់ទំនងប្រកបដោយសុវត្ថិភាព ការប្រើប្រាស់អេព(App) សម្រាប់កិច្ចប្រជុំពីចម្ងាយ ។ល។

ដោយឡែកថ្ងៃនេះក្រុមការងារគសក បានរៀបចំវេទិការៀនសូត្រស្តីពីទំនាក់ទំនងពត៌មាន និងបច្ចេកវិទ្យា លើកទី៣១ ក្រោមប្រធានបទ **ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងសិទ្ធិឌីជីថល** ដែលចូលរួមធ្វើការបង្ហាញដោយ **លោក ស ម៉ូរី** អ្នកគ្រប់គ្រងផ្នែកគោលនយោបាយ ច្បាប់ និងការតស៊ូមតិ នៃអង្គការគសក ព្រមទាំងវាគ្មិន មួយរូបទៀតគឺ **លោក មេធាវី ឌុច ពិសិដ្ឋ ស្ថាបនិកនៃក្រុមមេធាវី ធុរៈកិច្ចនិងសិទ្ធិមនុស្ស** បានចូលរួមធ្វើបទបង្ហាញលើប្រធានបទខាងលើ ដើម្បីចែកជូនជាចំណេះដឹងពាក់ព័ន្ធច្បាប់បច្ចេកវិទ្យាជូនដល់អង្គការសមាជិកដើម្បីជ្រាបជាពត៌មាន និងធ្វើការស្វែងយល់បន្ថែមលើផ្នែកគតិយុត្តពាក់ព័ន្ធនានា។ ដូចដែលលោក លោកស្រីបានជ្រាបរួចមកហើយថា៖ ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិច នាពេលសព្វថ្ងៃគឺមានភាពទូលំទូលាយ តែទោះបីជាយ៉ាងណាក៏ត្រូវស្ថិតនៅក្រោមការកំណត់របស់ច្បាប់។ តួយ៉ាងដូចជា អនុក្រឹត្យស្តីពីច្រកទ្វារជាតិអ៊ីនធើណេតដែលបង្កើតឡើងនាឆ្នាំ ២០២១ អនុក្រឹត្យស្តីពីការប្រើប្រាស់ដែនជាតិ និងសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ ឆ្នាំ២០២៣ សុទ្ធសឹងតែមានការកំណត់ពីការប្រើប្រាស់បណ្តាញអ៊ីនធើណេត ឬប្រព័ន្ធអេឡិចត្រូនិចក្នុង និងក្រៅប្រទេស ក្នុងគោលបំណងការពារសន្តិសុខជាតិ និងថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម វប្បធម៌ និងប្រពៃណីជាតិ។ ដោយយល់ឃើញថា ការបំពេញបន្ថែមចំណេះដឹងផ្នែកគតិយុត្តិពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងសិទ្ធិឌីជីថល គឺពិតជាមានភាពចាំបាច់សម្រាប់អង្គការសង្គមស៊ីវិលដើម្បីចូលរួមកាត់បន្ថយភាព


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

អសន្តិសុខផ្នែកបច្ចេកវិទ្យានៅក្នុងសង្គម ក៏ដូចជាការត្រៀមបង្ការហានិភ័យជាយថាហេតុនានា ដូចនេះ ហើយ អង្គការគសក បានរៀបចំវេទិការៀនសូត្រស្ដីពីបច្ចេកវិទ្យាទំនាក់ទំនងពត៌មាន នាព្រឹកនេះ។ ជាថ្មីម្ដងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់វាគ្មិនកិត្តិយស និងអស់លោក លោកស្រីជាអង្គការសមាជិក ទាំងអស់ដែលបានចូលរួមក្នុងវេទិការៀនសូត្រនាព្រឹកនេះ សូមប្រទះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកអង្គវេទិការៀនសូត្រចាប់ពីពេលនេះតទៅ។ សូមអរគុណ។

### 3.2 ការធ្វើបទបង្ហាញ

**លោក ស ម៉ូរី** ប្រធានគ្រប់គ្រងផ្នែក គោលនយោបាយ ច្បាប់ និងតស៊ូមតិ នៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា អញ្ជើញឡើងលើវេទិកាដើម្បីធ្វើបទបង្ហាញ អនុក្រិត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណែតជាតិដែលបានអនុម័តនៅឆ្នាំ២០២១ និង អនុក្រិត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណែត។ *(សូមមើលឯកសារក្នុងឧបសម្ព័ន្ធ)*








www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

**លោក ឌុច ពិសិដ្ឋ** ជាស្ថាបនិកក្រុមហ៊ុនមេធាវីធុរកិច្ច និងសិទ្ធិមនុស្ស អញ្ជើញ ធ្វើបទបង្ហាញស្តីពីសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមអ៊ីនធឺណិតដូចតទៅ៖




## ភាពខុសគ្នារវាងសន្តិសុខសាយប័រ (Cyber security) និងបទល្មើសបច្ចេកវិទ្យាព័ត៌មាន (Cyber crime)

| **សន្តិសុខសាយប័រ** (Cyber security) | **បទល្មើសបច្ចេកវិទ្យាព័ត៌មាន** (Cyber crime) |
| --- | --- |
| ជាបណ្តុំនៃការគ្រប់គ្រងផ្នែកបច្ចេកទេស និងបែបបទសម្រាប់មនុស្សអនុវត្តដើម្បីការពារស្ថាប័ន និងបុគ្គលពីការវាយប្រហាររបស់ឧក្រិដ្ឋជនលើប្រព័ន្ធបច្ចេកវិទ្យា | ជារបៀបនៃការប្រព្រឹត្តល្មើសលើប្រព័ន្ធបច្ចេកវិទ្យា |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## ១. ក្របខណ្ឌច្បាប់សិទ្ធិមនុស្ស

| ១.១. សិទ្ធិសេរីភាពបញ្ចេញមតិ | | | |
|---|---|---|---|
| មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ ១៩៩៣ | មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ | មាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ | មាត្រា ២៣ នៃសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស ឆ្នាំ២០១២ |
| "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ"។ | ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ | ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ | ទទួលស្គាល់ និងការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ |

- មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ៖ ទទួលស្គាល់ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧

## ២. ការវិភាគសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ

### *២.១. ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ និងអង្គភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗដែលមានលក្ខណៈទូលាយ*

- មាត្រា ៣(២០) នៃសេចក្តីព្រាងច្បាប់បានកំណត់និយមន័យហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ ថា "សំដៅដល់កុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រ ដែលក្រសួង ស្ថាប័នរដ្ឋ ឬអង្គភាពឯកជនប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ខ្លួន ដែលពាក់ព័ន្ធនឹងការថែរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សារធារណៈ សន្តិសុខសេដ្ឋកិច្ចជាតិ ឬហេដ្ឋារចនាសម្ព័ន្ធបម្រើប្រយោជន៍សាធារណៈ"។
- មាត្រា ៧ នៃសេចក្តីព្រាងច្បាប់នេះរៀបរាប់អំពីអង្គភាពហេដ្ឋរចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ ដែលក្នុងនោះរួមមានទាំង "នីតិបុគ្គលសាធារណៈនិងឯកជន" ដែលផ្តល់សេវាសារវន្តលើវិស័យ "ឌីជីថល" "ប្រព័ន្ធផ្សព្វផ្សាយ"។

## ២.២. រចនាសម្ព័ន្ធគ្រប់គ្រង៖ សិទ្ធិអំណាច និងឯករាជ្យភាព

- មាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រមានចែងអំពីការបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថលក្នុងគោលបំណងជានាពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការបំពេញមុខងារ។ ការប្រើប្រាស់ពាក្យពេចន៍ដែលមានលក្ខណៈទូលំទូលាយ ដូចជា "ការពារអត្ថប្រយោជន៍"។
- កថាខណ្ឌទី ២ នៃមាត្រា ៤ ក៏អនុញ្ញាតឱ្យបង្កើតអគ្គលេខាធិការដ្ឋាន ដែលនឹងត្រូវដឹកនាំសម្របសម្រួលដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- កថាខណ្ឌទី ៣ នៃមាត្រាដដែលនេះចែងថា ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការសន្តិសុខឌីជីថល និងអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ។
- មាត្រា ៥ នៃសេចក្តីព្រាងច្បាប់ផ្តល់សិទ្ធិអំណាចដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រាប់ចាប់តាំងពីការផ្តល់អាជ្ញាបណ្ណ ដោះស្រាយវិវាទ សម្របសម្រួល តាមដាន និងអនុវត្តភារកិច្ចចាំបាច់ផ្សេងទៀត ... ជាអាទិ៍។

## ២.៣. អំណាចក្នុងការតាមដាន ការគោរពសិទ្ធិមនុស្ស និងកង្វះការត្រួតពិនិត្យតាមផ្លូវតុលាការ

- សិទ្ធិអំណាចដែលគួរឱ្យព្រួយបារម្ភជាងគេគឺ សិទ្ធិរបស់គណៈកម្មាធិការសន្តិសុខឌីជីថលក្នុង "ការប្រមូលព័ត៌មាន ឬឯកសារពាក់ព័ន្ធ សាក្សី កស្តុតាងជសម្ភារៈ ដើម្បីវិភាគស្ថានភាព និងវាយតម្លៃផលប៉ះពាល់ពីការគំរាមកំហែងសន្តិសុខសាយប័រ ឬឧប្បត្តិហេតុសន្តិសុខសាយប័រ" ដូចមានចែងក្នុងមាត្រា ១៧ និងមាត្រា ១៨ នៃសេចក្តីព្រាងច្បាប់។ មាត្រា ១៨ ក៏អនុញ្ញាតឱ្យគណៈកម្មាធិការសន្តិសុខឌីជីថលអាច "ស្នើសុំ ឬចេញបញ្ជាឱ្យប្រើប្រាស់ប្រព័ន្ធដំណោះស្រាយដើម្បីគ្រប់គ្រង និងថែរក្សាសន្តិសុខសាយប័រ".
- នីតិបុគ្គលឯកជនជាពិសេស គឺថា អង្គភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗដែលមានកំណត់នៅក្នុងមាត្រា ៧ នៃសេចក្តីព្រាងច្បាប់រួមបញ្ចូលទាំងនីតិបុគ្គលឯកជន ដែលផ្តល់សេវាសារវន្ត ដូចជា ទូរ គមនាគមន៍ ឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ ដែលភាគច្រើនគឺជាស្ថាប័នក្នុងវិស័យឯកជន និងមិនមែនរដ្ឋាភិ បាល ដូចជាក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត សារព័ត៌មានឯករាជ្យ និងអង្គការសង្គមស៊ីវិលមួយចំនួនដែលផ្តល់សេវាដូចបានរៀបរាប់ខាងលើ។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

- មាត្រា ២១ និងមាត្រា ២២ នៃសេចក្តីព្រាងច្បាប់នេះផ្តល់សិទ្ធិអំណាចយ៉ាងច្រើនដល់គណៈកម្មាធិការសន្តិសុខឌីជីថលក្នុងការអាក់សេសកុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រ អាក់សេសទិន្នន័យ និងដកហូតកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ឬសម្ភារៈផ្សេងទៀត ជាដើម។
- ចំណុចវិជ្ជមានខ្លះដែរក្នុងមាត្រា ២១ នៃសេចក្តីព្រាងច្បាប់នេះ ដោយតម្រូវឱ្យគណៈកម្មាធិការសន្តិសុខឌីជីថលត្រូវសុំដីកាសម្រេចពីតុលាការជាមុន។ បណ្តឹងឧបាស្រ័យចំពោះដីកាតុលាការមិនអាចផ្អាកការអនុវត្តជាបណ្តោះអាសន្នលើប្រតិបត្តិការរបស់គណៈកម្មាធិការសន្តិសុខឌីជីថលទេ។
- មាត្រា ៣០ នៃសេចក្តីព្រាងច្បាប់អនុញ្ញាតឱ្យបុគ្គលមិនសុខចិត្តអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ចំពោះសេចក្តីសម្រេចរបស់មន្ត្រីទទួលបន្ទុកសន្តិសុខសាយប័រនៃគណៈកម្មាធិការសន្តិសុខឌីជីថល ឬមន្ត្រីអធិការកិច្ចសន្តិសុខសាយប័រ។
- មាត្រា ៣០ ដដែលនេះក៏អនុញ្ញាតឱ្យមានការប្តឹងតវ៉ាទៅតុលាការ ក្នុងរយៈពេល ៣០ ថ្ងៃ តែការប្តឹងទៅតុលាការនេះមិនអាចរាំងការអនុវត្តរបស់សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទេ។

### *២.៤. ការការពារទិន្នន័យបុគ្គល និងសិទ្ធិឯកជនភាព*

- មាត្រាមួយចំនួននៃសេចក្តីព្រាងច្បាប់ដែលតម្រូវឱ្យអង្គភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗផ្តល់ និងប្រមូល "ព័ត៌មាន" "ឈ្មោះនិងព័ត៌មានរបស់បុគ្គលទទួលខុសត្រូវហេដ្ឋារចនា សម្ព័ន្ធព័ត៌មានសំខាន់ៗ" "របាយការណ៍" "ស្នើសុំឬថតចម្លងព័ត៌មានឬឯកសារនានាដែលជាកម្មសិទ្ធិរបស់បុគ្គលពាក់ព័ន្ធ" "ឯកសារភស្តុតាងពាក់ព័ន្ធ" "សាក្សី" "ភស្តុតាងជាសម្ភារៈ" ទៅនិយ័តករមានសមត្ថកិច្ច និងគណៈកម្មាធិការសន្តិសុខឌីជីថល ដូចជាមាត្រា ១៣ និងមាត្រា ១៥ ដល់ មាត្រា ១៩។
- មាត្រា ២១ និងមាត្រា ២២ នៃសេចក្តីព្រាងច្បាប់ដែលអនុញ្ញាតឱ្យមានការ "អាក់សេសកុំព្យូទ័រ" និង "អាក់សេសទិន្នន័យ" ផងនោះ ជាការព្រួយបារម្ភផ្នែកសិទ្ធិមនុស្ស។

## ២.៥. បន្ទុកបន្ថែមលើនីតិបុគ្គលឯកជន និងទណ្ឌកម្មដែលពុំសមាមាត្រ

- សេចក្តីព្រាងច្បាប់នេះតម្រូវឱ្យអង្គភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗត្រូវមានតួនាទី និងការកិច្ចច្រើនដែលជាបន្ទុកបន្ថែមលើវិស័យឯកជន។
- មាត្រា ៨ នៃសេចក្តីព្រាងច្បាប់មានចែងអំពីលក្ខខណ្ឌតម្រូវនៃតួនាទី និងភារកិច្ចរបស់អង្គភាពហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ រួមទាំងនីតិបុគ្គលឯកជន ដែលមានចាប់ពីការបង្ការទប់ស្កាត់ ដោះស្រាយ និងកាត់បន្ថយហានិភ័យ រៀបចំប្រព័ន្ធគ្រប់គ្រង ថែរក្សា វាយតម្លៃហានិភ័យ ធ្វើបច្ចុប្បន្នភាព រៀបចំអង្គភាពជំនាញ រៀបចំគម្រោងចំណាយ និងសហការជាមួយស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធនានាជុំវិញបញ្ហាគ្រប់គ្រង និងថែរក្សាសន្តិសុខសាយប័រ។
- មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់ក៏តម្រូវឱ្យនីតិបុគ្គលឯកជន "ត្រូវធ្វើការវាយតម្លៃហានិភ័យនៃការគ្រប់គ្រង និងការថែរក្សាសន្តិសុខសាយប័ររបស់ខ្លួនយ៉ាងតិចមួយដងក្នុងមួយឆ្នាំ" និង "ត្រូវបញ្ជូនរបាយការណ៍នេះទៅនិយ័តករមានសមត្ថកិច្ច" និង "ចម្លងជូនគណៈកម្មាធិការសន្តិសុខឌីជីថល"។

- មិនអនុវត្តតាមត្រង់ចំណុច "វាយតម្លៃហានិភ័យ" អាចនឹងទទួលរងនូវការដាក់ពិន័យតាមមាត្រា ៣៩ ជាទឹកប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់រហូតទៅដល់ ៨០ លានរៀល ហើយបុគ្គលដែលទទួលខុសត្រូវអង្គភាពខ្លួនអាចនឹងប្រឈមនឹងទោសពន្ធនាគាររហូតដល់ ១ ឆ្នាំ និងប្រាក់ពិន័យកើនទ្វេដងទៀត។
- បើមិនបាន "ផ្តល់របាយការណ៍ពីការវាយតម្លៃហានិភ័យ" នេះស្របតាមមាត្រា ១៣ ទេ បុគ្គលដែលទទួលខុសត្រូវក្នុងនីតិបុគ្គលឯកជននោះអាចនឹងទទួលរងនូវការពិន័យជាប្រាក់រហូតដល់ ១០០ លានរៀល តាមមាត្រា ៤០ ហើយបុគ្គលដែលទទួលខុសត្រូវអង្គភាពខ្លួនអាចនឹងប្រឈមនឹងទោសពន្ធនាគាររហូតដល់ ១ ឆ្នាំ និងប្រាក់ពិន័យកើនទ្វេដងទៀត។
- ទោសពិន័យជាប្រាក់ និងពន្ធនាគារនេះហាក់ដូចជាមិនសមាមាត្រស្របតាមលក្ខខណ្ឌនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

- សេចក្តីព្រាងច្បាប់នេះចែងនៅមានលក្ខណៈទូលំទូលាយ ដោយមិនមានចែងជាក់លាក់អំពីចេតនាទុច្ចរិត និងទំនាក់ទំនងគ្នាដោយផ្ទាល់រវាងហេតុ និងផលនៃអំពើ ឬសកម្មភាពរបស់នីតិបុគ្គលឯកជន ឬបុគ្គលទទួលខុសត្រូវក្នុងសេចក្តីព្រាងច្បាប់នេះ យើងសង្កេតឃើញថាការដាក់ទោសទណ្ឌលើអ្នកទទួលខុសត្រូវហាក់ដូចជាហួសហេតុ និងមិនសមាមាត្រាទាល់តែសោះចំពោះអំពើ (សូមមើលពីមាត្រា៣៧ ដល់ ៤៥)។
- នីតិបុគ្គលឯកជនក៏តម្រូវឱ្យស្នើសុំអាជ្ញាបណ្ណសម្រាប់សេវាសន្តិសុខសាយប័រពីក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ផងដែរ យោងតាមមាត្រា ២៣។
- ការពិនិត្យ និងផ្តល់អាជ្ញាបណ្ណនេះគួរតែត្រូវគ្រប់គ្រងដោយស្ថាប័នឯករាជ្យ ជាជាងក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍ដែលស្ថាប័នរាជរដ្ឋាភិបាល។

### 5. បិទកម្មវិធី

លោក ចាន់ ណាត សមាជិកក្រុមការងារបច្ចេកទេសICT និងជានាយកអង្គការមហាគ្រួសារអោយធី បានថ្លែងអំណរគុណដល់វាគ្មិន និងអ្នកចូលរួមទាំងអស់ដែលរួមចំណែកធ្វើអោយវេទិការៀនសូត្រនេះកាន់តែមានភាពសកម្ម និងផ្តល់ជាពុទ្ធិដល់អង្គវេទិកាទាំងមូល។

Document.rar

### 6. ឧបសម្ព័ន្ធ

### 7. របៀបវារៈ

| Time | Key Contents | Resource persons |
|---|---|---|
| 08:00AM-08:30AM | ការចុះឈ្មោះ | ក្រុមការងារគសក |
| 08:30AM-08:40AM | ការណែនាំពីគោលបំណងនៃវេទិកា | ក្រុមការងារគសក |
| 08:40AM-08:50AM | កិច្ចស្វាគមន៍ | **លោកច័ន្ទ ភក្តី** ប្រធានកម្មវិធីផ្នែកសមាជិក និងការកៀរគរធនធាននៃអង្គការគសក |
| 8:50AM-10:00AM | **បទបង្ហាញស្តីពី:**<br>- អនុក្រិត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណែតជាតិដែលបានអនុម័តនៅឆ្នាំ២០២១ និង អនុក្រិត្យស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណែត | **លោក ស ម៉ូរី** ប្រធានគ្រប់គ្រងផ្នែក គោលនយោបាយ ច្បាប់ និងតស៊ូមតិ នៃអង្គការគសក |

| | | |
|---|---|---|
| | - សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ព ត៍មាន | |
| 10:00AM-10:15AM | សម្រាក | |
| 10:15AM-11:50AM | **បទបង្ហាញស្តីពី:**<br>- សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមអ៊ីនធឺណិត<br>- សំណួរ &ចម្លើយ | **លោក ឌុច ពិសិដ្ឋ** ជាស្ថាបនិក ក្រុមហ៊ុនមេធាវីធុរកិច្ច និងសិទ្ធិមនុស្ស |
| 11:50AM-12:00PM | **បិទកម្មវិធី** | **លោក ចាន់ ណាត** សមាជិកក្រុមការងារបច្ចេកទេសICT និងជានាយកអង្គការមហាគ្រួសារអាយធី |
| 12:00PM-1:30PM | អាហារថ្ងៃត្រង់ | |

***សំគាល់:*** អង្គការគសក នឹងប្រើប្រាស់រូបភាពនៃវេទិការៀនសូត្រនេះដើម្បីបង្ហោះក្នុងវេបសាយអង្គការគសក និងការប្រើប្រាស់ផ្លូវការផ្សេងៗ។ អង្គការគសក រក្សាសិទ្ធិក្នុងការផ្លាស់ប្តូររបៀបវារៈផ្អែកតាមភាពចាំបាច់របស់វាគ្មិន និងពេលវេលាជាក់ស្តែង។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia